**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តឧត្តរមានជ័យ**
លេខៈ០៧២ សជណ.ឧជ

ឧត្តរមានជ័យ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០១៣

**ជម្រាបមក**

**លោកអភិបាលក្រុង-ស្រុក លោកចៅសង្កាត់-មេឃុំ ទាំងអស់ក្នុងខេត្តឧត្តរមានជ័យ**

**កម្មវត្ថុ៖** ស្តីពីការប្រមូលពន្ធប្រថាប់ត្រា លើការផ្ទេរសិទ្ធិកាន់កាប់ដីមិនចុះបញ្ជី (គ្មានបណ្ណកម្មសិទ្ធិ) ក្រោមរូបភាពជាការលក់ ការដោះដូរ និង ការទទួលអំណោយ ដែលចុះហត្ថលេខាដោយចៅសង្កាត់-មេឃុំ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សាលាខេត្តឧត្តរមានជ័យបានពិនិត្យឃើញថា សកម្មភាពទិញលក់ដីមិនចុះបញ្ជីមានចំនួនច្រើន ជារៀងរាល់ខែ រាល់ឆ្នាំ ប៉ុន្តែម្ចាស់ដីមួយចំនួនមិនបានទៅបង់ពន្ធប្រថាប់ត្រាឡើយ ដែលធ្វើអោយបាត់ចំណូលថវិកាខេត្តមួយចំនួនធំ។ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ឆ្នាំ១៩៩៥ បានកំណត់ថា " ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ រឺ ការផ្ទេរសិទ្ធិកាន់កាប់ដីក្រោមរូបភាពជាការលក់ ការដោះដូរ ការទទួលអំណោយ ការដាក់ភាគទុនក្នុងក្រុមហ៊ុន ត្រូវតែបង់ពន្ធប្រថាប់ត្រា " (៤% លើតម្លៃទិញជាក់ស្តែង) ។

អភិបាលខេត្តនឹងបញ្ជូនមន្ត្រីពន្ធដារ ដើម្បីពិនិត្យសៀវភៅលេខចេញនៅឃុំ-សង្កាត់ ជារៀងរាល់ខែ ករណីពិនិត្យឃើញថា ចៅសង្កាត់-មេឃុំ បានចុះហត្ថលេខាបញ្ជាក់លើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីមិនចុះបញ្ជីមុនពេលបង់ពន្ធប្រថាប់ត្រានោះ ចៅសង្កាត់-មេឃុំ ត្រូវចេញសងថ្លៃពន្ធប្រថាប់ត្រា ហើយត្រូវពិន័យជាប្រាក់មួយដងស្មើប្រាក់ពន្ធត្រូវបង់ និង ត្រូវទទួលខុសត្រូវចំពោះមុខអាជ្ញាធរសេវនកម្មជាតិ ។

ដើម្បីអនុវត្តកិច្ចការនេះទទួលបានលទ្ធផលល្អប្រសើរ សូមលោកអភិបាលក្រុង-ស្រុក ចៅសង្កាត់មេឃុំ ស្មៀនសង្កាត់-ឃុំ ជួយជំរុញម្ចាស់ដីទាំងអស់អោយទៅបង់ពន្ធនៅអង្គភាពពន្ធដារ ដើម្បីបង្កើនចំណូលថវិកាខេត្ត ។

ចំពោះស្មៀនឃុំ-សង្កាត់ បើសិនចៅសង្កាត់-មេឃុំ ចុះហត្ថលេខាបំពានការណែនាំនេះ មិនត្រូវបោះត្រាឲ្យឡើយ ហើយត្រូវរាយការណ៍តាមទូរសព្ទមកសាលាខេត្ត ឬមន្ត្រីពន្ធដារ ដើម្បីជួយអន្តរាគមន៍ ។

ទទួលបានការជូនដំណឹងនេះ សូមលោកអភិបាលក្រុង-ស្រុក ចៅសង្កាត់-មេឃុំ ជួយណែនាំដល់មន្ត្រីក្រោមឱវាទ ដើម្បីអនុវត្តការងារនេះអោយបានម៉ឺងម៉ាត់ជាទីបំផុត ។

សូមលោក លោកស្រី ទទួលនូវការរាប់អានពីខ្ញុំ។

**អភិបាលខេត្ត**

ស_ថាវី

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាខាពន្ធដារខេត្តឧត្តរមានជ័យ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ